ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**

**<u>សាលាដំបូងខេត្តក្រចេះ</u>**

សាលក្រមរដ្ឋប្បវេណី

លេខ: ១០៤ "ឈ"

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

សំណុំរឿងរដ្ឋប្បវេណីលេខ:៩២

ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤

**បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤ និងប្រកាសសាលក្រមជាសាធារណៈ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។**

-លោក [redacted]ក្រមសាលាដំបូងខេត្តក្រចេះ។

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ។

**រវាងដើមចោទឈ្មោះ** [redacted] **ស៊ូលីន** ភេទស្រី អាយុ ២០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ឪពុកឈ្មោះ [redacted]ឿន (រ) ម្តាយឈ្មោះ [redacted]ាសនា (រ) ប្តីឈ្មោះ [redacted]ហុច មានកូន០១នាក់ ដែលមានអ្នកតំណាងដោយអាណត្តិគឺលោកមេធាវី [redacted]

**និងចុងចម្លើយឈ្មោះ**[redacted]**លុច** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅ[redacted] ឪពុកឈ្មោះ [redacted]ណូ (រ) ម្តាយឈ្មោះ [redacted] ហ៊ាង (រ) ប្រពន្ធឈ្មោះ [redacted] ស៊ូលីន មានកូន ០១នាក់។

**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការសម្រេច:</u>**

១.នាងខ្ញុំឈ្មោះ [redacted] ស៊ូលីន សុំបំបែកលែងលះជាមួយឈ្មោះ [redacted] លុច។

២.ទទួលស្គាល់នាងខ្ញុំឈ្មោះ [redacted] ស៊ូលីន ជាអ្នកមានអំណាចមេបាលើកូន០១នាក់ កូនឈ្មោះ [redacted] លី ស៊ីញ ភេទប្រុស កើតថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣។

៣.សុំអាហារកាតព្វកិច្ចចិញ្ចឹមកូនពីឈ្មោះ [redacted] លុច ជាឪពុកចំនួន៤០០,០០០(សែសិបម៉ឺន)រៀល ក្នុងមួយខែរហូតកូនមាននីតិភាព។

៤.បង្គាប់ឲ្យឈ្មោះ [redacted] លុច ប្រគល់ប្រាក់ចំនួន១៥០០$ មកឲ្យនាងខ្ញុំជាដើមចោទ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុកកូនចំនួន០១ ច្បាប់។

**<u>អង្គហេតុ</u>**

**១-អង្គហេតុ:**

-កាលពីអំឡុងឆ្នាំ២០២២ ដើមចោទឈ្មោះ [redacted] ស៊ូលីន បានរៀងអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] លុច នឹងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ២ សៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលាឃុំថ្មីត្រឹមត្រូវតាមច្បាប់។ បន្ទាប់ពីពេលរៀបអាពាហ៍ពិពាហ៍



Scanned with CamScanner

ហើយភាគីទាំងពីរនាក់មិនដែលមានទំនាស់អ្វីនោះទេ ទើបតែនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ ដើមចោទឈ្មោះ [redacted] ស៊ូលីន បានឈ្លោះគ្នាជាមួយចុងចម្លើយឈ្មោះ [redacted] លុច ហើយចុងចម្លើយឈ្មោះ [redacted] លុច បានវេចបង្វិច និងបានយកកូនតូចដែលមានអាយុ ៨ខែ ចុះចេញពីផ្ទះ។ កន្លងមកដើមចោទ និងចុងចម្លើយឧស្សាហ៍មានទំនាសជាមួយគ្នាដែរ ហើយពេលមានទំនាស់ចុងចម្លើយឈ្មោះ [redacted] លុច តែងតែចុះចេញពីផ្ទះ ដែលទង្វើទាំងអស់នេះហើយធ្វើឲ្យដើមចោទអស់មនោសញ្ចេតនា ក្នុងការរួមរស់នៅជាមួយគ្នាតទៅទៀត។ ក្នុងការរួមរស់នៅជាមួយគ្នាបង្កើតកូនប្រុសម្នាក់ឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ហើយចំពោះទ្រព្យសម្បត្តិរួមមាន: គោយន្តកន្ត្រៃយ៍ចំនួន០១ គ្រឿង, រថយន្ត ម៉ាកសាំងយ៉ុង ពណ៌សំបកឌីឡែក គ្មានស្លាកលេខ ចំនួន០១គ្រឿង និងមេគោចំនួន០១ក្បាល និងទ្រព្យសម្បត្តិឡែកគឺគ្មានទេ។

**២-សេចក្តីថ្លែងការណ៍របស់គូភាគី**

**ក-**ដើមចោទឈ្មោះ [redacted] **ស៊ូលីន** បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: នាងខ្ញុំឈ្មោះ [redacted] ស៊ូលីន បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] លុច នៅឆ្នាំ២០២២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ: ២ សៀវភៅអាពាហ៍ពិពាហ៍លេខ:០១/២០២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលាឃុំថ្មី។ ក្រោយពីពេលរៀបអាពាហ៍ពិពាហ៍ហើយយើងទាំងពីរនាក់មិនដែលមានទំនាស់អ្វីនោះទេ ទើបតែនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ នាងខ្ញុំបានឈ្លោះគ្នាជាមួយឈ្មោះ [redacted] លុច ដោយនាងខ្ញុំបាននិយាយថា "បើឈប់ស្រឡាញ់ខ្ញុំហើយ ដោះលែងខ្ញុំទៅ" ហើយឈ្មោះ [redacted] លុច បានវេចបង្វិច និងបានយកកូនតូចដែលមានអាយុ ៨ខែ ចុះចេញពីផ្ទះ រហូតមកដល់បច្ចុប្បន្ននេះ។ កន្លងមកពួកខ្ញុំឧស្សាហ៍មានទំនាសជាមួយគ្នាដែរ ហើយពេលមានទំនាស់ឈ្មោះ [redacted] លុច តែងតែចុះចេញពីផ្ទះ ដែលទង្វើទាំងអស់នេះហើយ ធ្វើឲ្យនាងខ្ញុំអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាមួយគ្នាតទៅទៀត។ ក្នុងការរួមរស់នៅជាមួយគ្នាបង្កើតកូនប្រុសម្នាក់ឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ហើយនាងខ្ញុំសុំជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣។ ចំពោះទ្រព្យសម្បត្តិរួមមាន: គោយន្តកន្ត្រៃយ៍ចំនួន០១ គ្រឿង, រថយន្ត ម៉ាកសាំងយ៉ុង ពណ៌សំបកឌីឡែក គ្មានស្លាកលេខ ចំនួន០១គ្រឿង និងមេគោចំនួន ០១ក្បាល និងទ្រព្យសម្បត្តិឡែកគឺគ្មានទេ។ ចំពោះអាហារកាតព្វកិច្ចគឺនាងខ្ញុំមិនទាមទារទេ ពីព្រោះនាងខ្ញុំអាចចិញ្ចឹមកូនបានដោយខ្លួនឯង ដោយសារនាងខ្ញុំការងារច្បាស់លាស់មួយ ហើយប្រាក់ចំនួន១,៥០០(មួយពាន់បំរយ)ដុល្លារអាមេរិក គឺនាងខ្ញុំមិនទាមទារនោះទេ។ ចំពោះគោយន្តកន្ត្រៃយ៍ចំនួន០១គ្រឿង គឺនាងខ្ញុំសុំជាអ្នកគ្រប់គ្រង ហើយនាងខ្ញុំសុំប្រគល់រថយន្ត ម៉ាកសាំងយ៉ុង ពណ៌សំបកឌីឡែក គ្មានស្លាកលេខ ឲ្យឈ្មោះ [redacted] លុច ជាអ្នកគ្រប់គ្រង ដោយមិនចាំបាច់ឲ្យតុលាការធ្វើការបែងចែកនោះទេ ពីព្រោះនាងខ្ញុំបានចែកគ្នារួចហើយ ចំពោះមេគោចំនួន០១ក្បាល ពណ៌ក្រហមលាយស ដែលបានប្រវាស់ឲ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ណាន មានទីលំនៅសព្វ [redacted]



Scanned with CamScanner

[redacted] នាងខ្ញុំសុំជាអ្នកគ្រប់គ្រងថែរក្សាទុកឱ្យកូន។ ចំពោះបំណុលរួម និងបំណុលដោយឡែកគឺ គ្មានទេ។

-សំណូមពរសុំឱ្យតុលាការចេញសាលក្រមសម្រេចផ្លូវ:

១.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] លុច តាមច្បាប់។

២.សុំជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣។

៣.ចំពោះប្រាក់ប្រដាប់ក្តីគឺនាងខ្ញុំសុំចិត្តទទួលបន្ទុក។

**ខ**-អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] បានថ្លែងការណ៍ថា: ខ្ញុំឯកភាពតាមការថ្លែងការណ៍របស់ដើមចោទទាំងស្រុង។

**គ**-ចុងចម្លើយឈ្មោះ [redacted] **លុច** បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្ញុំសុំរក្សាខ្លឹមសារនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីពីរ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ទុកនៅដដែលដូចខាងក្រោម៖ ខ្ញុំមិនឯកភាពតាមការប្តឹងសុំលែងលះរបស់ដើមចោទឈ្មោះ [redacted] ស៊ូលីន ទេ ពីព្រោះខ្ញុំនៅស្រលាញ់គាត់ ហើយក្នុងចំណងអាពាហ៍ពិពាហ៍គឺបង្កើតបានកូនប្រុសម្នាក់ឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ដោយខ្ញុំយល់ព្រមប្រគល់ឱ្យដើមចោទឈ្មោះ [redacted] ស៊ូលីន ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣។ ចំពោះទ្រព្យសម្បត្តិរួមមាន៖ គោយន្តកន្ត្រៃយ៍ចំនួន០១គ្រឿង និងរថយន្ត ម៉ាកសាំងយ៉ុង ពណ៌សំបកឪឡឹក គ្មានស្លាកលេខ និងគោចំនួន០១ ក្បាល ពណ៌ក្រហមលាយស ហើយខ្ញុំយល់ព្រមទទួលយករថយន្ត ម៉ាកសាំងយ៉ុង ពណ៌សំបកឪឡឹក គ្មានស្លាកលេខ ដោយខ្ញុំយល់ព្រមប្រគល់គោយន្តកន្ត្រៃយ៍ចំនួន០១គ្រឿង ឱ្យទៅដើមចោទឈ្មោះ [redacted] ស៊ូលីន អ្នកគ្រង់គ្រង និងមិនចាំបាច់ឱ្យតុលាការធ្វើការបែងចែកនោះទេ ។ ចំពោះមេគោចំនួន០១ ក្បាល ពណ៌ក្រហមលាយស ដែលបានប្រវាស់ឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ណាន មានទីលំនៅសព្វថ្ងៃនៅ [redacted] គឺខ្ញុំយល់ព្រមប្រគល់ឱ្យកូនប្រុសឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ដោយដើមចោទឈ្មោះ [redacted] ស៊ូលីន ជាអ្នកគ្រប់គ្រងទុកឱ្យកូន។ រីឯអាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនគឺខ្ញុំបង់តាមលទ្ធភាព។ ចំពោះទ្រព្យសម្បត្តិដោយឡែក និងបំណុលរួមគឺគ្មានទេ។

## **ការសំអាងហេតុ**

១-ដើមចោទឈ្មោះ [redacted] ស៊ូលីន និងចុងចម្លើយឈ្មោះ [redacted] លុច ពិតជាសហព័ទ្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសេចក្តីថ្លែងការណ៍របស់គូភាគី និងសំបុត្រអាពាហ៍ពិពាហ៍លេខ: ២ សៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០២២ ឆ្នាំ២០២២ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ឃុំថ្មីជាភស្តុតាងស្រាប់។

២-ដើមចោទបានប្តឹងសុំលែងលះពីចុងចម្លើយដោយសំអាងថា: ខ្លួន និងចុងចម្លើយមានការរស់នៅមិន



Scanned with CamScanner

ចុះសម្រុងនឹងគ្នា ហើយពួកខ្លួនបានបែកលំនៅឋានគ្នាកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ រហូតមកដល់បច្ចុប្បន្ន ជាហេតុបណ្តាលឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយចុងចម្លើយតទៅទៀត។ រីឯចុងចម្លើយឈ្មោះ [redacted] លុច មិនឯកភាពក្នុងការប្តឹងសុំលែងលះរបស់ដើមចោទឡើយ ពីព្រោះខ្លួននៅស្រលាញ់ដើមចោទ។ ដូច្នេះ យល់ឃើញថាចុងចម្លើយគ្មានមានបំណងក្នុងការលែងលះជាមួយដើមចោទនោះទេ ប៉ុន្តែស្ថានភាពរបស់គូភាគីក្នុងការរស់នៅជាប្តីប្រពន្ធ គឺមិនអាចរក្សាទំនាក់ទំនងអាពាហ៍ពិពាហ៍ និងមានស្ថានភាពធ្ងន់ធ្ងរដែលគ្មានសង្ឃឹមថានឹងអាចស្តារឡើងវិញបាន។ ហេតុនេះការប្តឹងសុំលែងលះរបស់ដើមចោទ គឺមានមូលហេតុត្រឹមត្រូវតាមមាត្រា៩៧៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ គប្បីតុលាការធ្វើការពិនិត្យ និងពិចារណា ដោយផ្អែកទៅលើឆន្ទៈរបស់ដើមចោទក៏ដូចជាមូលហេតុដែលនាំឱ្យចំណងអាពាហ៍ពិពាហ៍នេះមិនអាចធ្វើបដិទានវិញបាន។

៣-គូភាគីបានថ្លែងការណ៍ថា: ការរស់នៅជាប្តីប្រពន្ធបង្កើតបានកូនប្រុសម្នាក់ឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ដោយដើមចោទសុំជាអ្នកមានអំណាចមេបាលើកូន និងមិនទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនឡើយ ហើយចុងចម្លើយបានយល់ព្រមប្រគល់កូនប្រុសឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ឱ្យទៅដើមចោទជាអ្នកមានអំណាចមេបា។ ដូច្នេះ ការថ្លែងការណ៍នេះមានភាពស៊ីសង្វាក់ជាមួយសំបុត្រកំណើតលេខ: ៦៦ សៀវភៅកំណើតលេខ:០២/២០២៣ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] លីស៊ីញ បញ្ជាក់ថា: ឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ពិតជាកូនរបស់គូភាគីប្រាកដមែន ដែលត្រង់ចំណុចនេះ គប្បីតុលាការសម្រេចកំណត់យកអ្នកមានអំណាចមេបាតាមមាត្រា១០៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

៤-ដើមចោទបានថ្លែងការណ៍ថា: ខ្លួនសុំមិនទាមទារប្រាក់ចំនួន១,៥០០(មួយពាន់ប្រាំរយ)ដុល្លារអាមេរិកនោះទេ ប៉ុន្តែខ្លួនសុំជាអ្នកគ្រប់គ្រងគោយន្តកន្ត្រៃយ៍ចំនួន០១គ្រឿង និងមេគោចំនួន០១ក្បាល ពណ៌ក្រហមលាយស ដែលបានប្រវាស់ឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ណាន មានទីលំនៅសព្វថ្ងៃ[redacted] និងយល់ព្រមប្រគល់រថយន្តចំនួន ០១គ្រឿង ម៉ាកសាំងយ៉ុង ពណ៌សំបកឪឡឹក គ្មានស្លាកលេខ ឱ្យចុងចម្លើយឈ្មោះ [redacted] លុច ជាអ្នកគ្រប់គ្រង ដោយមិនចាំបាច់ឱ្យតុលាការធ្វើការបែងចែកនោះទេ ពីព្រោះខ្លួនបានចែកគ្នារួចហើយ។ រីឯចុងចម្លើយបានថ្លែងការណ៍ថា ខ្លួនយល់ព្រមទទួលយករថយន្តចំនួន ០១គ្រឿង ម៉ាកសាំងយ៉ុង ពណ៌សំបកឪឡឹក គ្មានស្លាកលេខ ហើយខ្លួនយល់ព្រមប្រគល់គោយន្តកន្ត្រៃយ៍ចំនួន០១គ្រឿង ឱ្យទៅដើមចោទឈ្មោះ [redacted] ស៊ូលីន ជាអ្នកគ្រង់គ្រង។ រីឯមេគោចំនួន០១ក្បាល ពណ៌ក្រហមលាយស ដែលបានប្រវាស់ឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ណាន មានទីលំនៅសព្វថ្ងៃនៅ[redacted] គឺខ្លួនយល់ព្រមប្រគល់ឱ្យកូនប្រុសឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ហើយដើមចោទឈ្មោះ [redacted] ស៊ូលីន ជាអ្នកគ្រប់គ្រងទុកឱ្យកូន ដោយ



Scanned with CamScanner

មិនចាំបាច់ឲ្យតុលាការធ្វើការបែងចែកនោះទេ ដែលចំណុចនេះ គប្បីតុលាការមិនលើកយកមកពិនិត្យ និងពិចារណាឡើយ។ ចំពោះទ្រព្យសម្បត្តិដោយឡែក និងបំណុលរួម គឺគ្មានទេ ដែលចំណុចនេះ គប្បីតុលាការមិនលើកយកមកពិចារណា និងសម្រេចឡើយ។

៥-ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ដើមចោទ។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ [redacted] ស៊ូលីន ផ្តាច់នីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] លុច តាមមាត្រា៩៧៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

២-កំណត់យកដើមចោទឈ្មោះ [redacted] ស៊ូលីន ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] លីស៊ីញ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ចុងចម្លើយដែលពុំមានអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ រីឯដើមចោទដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ចុងចម្លើយ តាមមាត្រា១០៣៧ និងមាត្រា១០៤០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

សាលក្រមនេះបានបញ្ចប់នីតិវិធីនៃការទាញហេតុផលផ្ទាល់នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង០២ និង៣០នាទី រសៀល និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង០៩ និង០០នាទី ព្រឹក ចំពោះមុខដើមចោទឈ្មោះ [redacted] ស៊ូលីន, ចុងចម្លើយឈ្មោះ [redacted] លុច និងអ្នកតំណាងដោយអាណត្តិឲ្យដើមចោទគឺលោកមេធាវី [redacted]

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ហត្ថលេខា និងត្រា**

[redacted]

---

**បានឃើញ**
**ចៅក្រម**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ក្រចេះ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner